**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាសិក្ខាសាលាសម្រាប់ការត្រាស់ហៅនៅភ្នំពេញថ្មី**
**ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨**
***ចូរស្ថិតនៅជាប់នឹងខ្ញុំ***

អត្ថបទទី១៖ កក ៩,២៦-៣១
អត្ថបទទី២៖ ១យហ ៣,១៨-២៤
ដំណឹងល្អ៖ យហ ១៥,១-៨

បងប្អូនជាទីស្រលាញ់

ម្សិលមិញ យើងបានជួបជុំគ្នារិះគិតជាពិសេសសារលិខិតរបស់សម្តេចប៉ាប ណែនាំឲ្យយើងយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលណែនាំឲ្យយើងគិតពិចារណាអំពីជីវិតរបស់យើង និងឲ្យយកចិត្តទុកដាក់អនុវត្ត។ ដូច្នេះ នៅពេលនេះខ្ញុំឆ្លៀតឱកាសដើម្បីនិយាយម្តងទៀត «**យុវជនជាបច្ចុប្បន្ននៃព្រះសហគមន៍**»។ នៅពេលនេះ យើងពោរពេញដោយកម្លាំង អំណរសប្បាយ គំនិតយ៉ាងច្រើន និងពោរពេញដោយសុបិន្តសម្រាប់ជីវិតដើម្បីកសាងពិភពថ្មី។

យុវជន យុវនារីត្រូវតែយល់ថា យើងជាបច្ចុប្បន្ននៃព្រះសហគមន៍ យើងណែនាំឲ្យព្រះសហគមន៍មានកម្លាំងពិសេស និងពោរពេញដោយអំណរសប្បាយ ដែលចេញពីដួងចិត្តរបស់យើង ជីវិតរបស់យើង។ អ្វីដែលយើងនឹកឃើញថា ខ្ញុំចង់កសាងជីវិតរបស់ខ្ញុំយ៉ាងម៉េច ដូច្នេះថ្ងៃនេះ ខ្ញុំចេញកម្លាំងដើម្បីថ្ងៃស្អែកជីវិតរបស់ខ្ញុំ ប្រកបដោយសុបិនរបស់ខ្ញុំនៅពេលនេះ។ នៅពេលនេះជាពេលវេលា ដើម្បីកសាងអនាគត ដើម្បីសាងសង់ព្រះសហគមន៍ ដោយចេញ កម្លាំង អំណរសប្បាយរបស់យើង ដោយណែនាំឲ្យព្រះសហគមន៍របស់យើង មានជីវិតដ៏បរិបូរណ៍។

យើងបានស្តាប់អត្ថបទដំណឹងល្អ ព្រះយេស៊ូណែនាំឲ្យយើងចូលទៅក្នុងទំនាក់ទំនងដែលយើងត្រូវតែមានជាមួយព្រះយេស៊ូ។ នៅថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក ព្រះអង្គបានជ្រើសរើសយើង ដើម្បីទៅជាបុត្រធីតារបស់ព្រះអង្គ។ ព្រះយេស៊ូដែលមានព្រះបន្ទូលថា «**ខ្ញុំហ្នឹងហើយ ជាដើមទំពាំងបាយជូរដ៏ពិតប្រាកដ រីឯមែកណាមានផ្លែ ព្រះអង្គលួសមែកនោះ ដើម្បីឲ្យមានផ្លែកាន់តែច្រើនឡើងៗ ពាក្យដែលខ្ញុំបានប្រាប់ ធ្វើឲ្យអ្នករាល់គ្នាបានបរិសុទ្ធរួចទៅហើយ ចូរស្ថិតនៅជាប់នឹងខ្ញុំ**»។ ថ្ងៃនេះ ព្រះយេស៊ូឲ្យយើងទៅជាអង្គតែមួយជាមួយព្រះយេស៊ូ អត់មានព្រះយេស៊ូនៅខាងនេះ ហើយជីវិតរបស់យើងនៅខាង

នោះ។ មានតែដើមតែមួយគឺដើមទំពាំងបាយជូរ ដែលមានគល់វាដ៏សំខាន់ណាស់ នៅរៀងរាល់ឆ្នាំវាចេញមែក មែកចេញវែងល្អមដើម្បីឲ្យមានផ្លែទំពាំងបាយជូរ ដែលយើងកាត់ធ្វើស្រាទំពាំងបាយជូរ។ តាមពិតទំពាំងបាយជូរនិងផ្កាកូលាប ប្រហាក់ប្រហែលគ្នា។ មានមែកមួយ ហើយប្រសិនបើរាល់ដងវាចេញផ្លែហើយ យើងលួសវា ពេលយើងកាត់ស្អាត វាចេញផ្លែច្រើន។ ពេលយើងកាត់ជារៀងរាល់ឆ្នាំ មួយឆ្នាំទៅមួយឆ្នាំ វាចេញមែកថែមទៀត និងទំពាំងបាយជូរចេញផ្លែយ៉ាងច្រើន ដែលឆ្ងាញ់ទៅៗផ្អែមទៅៗ។ ដូច្នេះជីវិតរបស់យើងដូចគ្នាដែរ បើសិនជាយើងមិនជាប់ជាមួយព្រះយេស៊ូ មានតែជាមួយគល់ មែកវាអត់មានផ្លែផ្ទុយទៅវិញទៅជាក្រៀម ស្វិតអត់មានផ្លែនិងងាប់។

ព្រះយេស៊ូ ណែនាំឲ្យយើងចូលយ៉ាងជ្រៅបំផុតក្នុងជីវិតជាគ្រីស្តបរិស័ទ យើងជាប់ជាមួយព្រះយេស៊ូមុនគេបង្អស់។ រឿងមួយមានកូនក្មេងកំពុងមើល មនុស្សម្នាក់ដែលមានគ្រោះថ្នាក់ចរាចរណ៍ស្លាប់ និងមានបូជាចារ្យម្នាក់ដែលឃើញគ្រោះថ្នាក់ចរាចរណ៍នេះ គាត់កំពុងបើកឡានគាត់ចេញពីឡាន គាត់យកកន្សែងពណ៌ស្វាយតូចរបស់គាត់ មានសៀវភៅអធិដ្ឋានមួយ មានប្រេងគាត់ធ្វើអគ្គសញ្ញាឲ្យអ្នកជំងឺដើម្បីឲ្យគាត់មានកម្លាំង ហើយកូនក្មេងនេះកំពុងមើល លទ្ធផលចុងក្រោយអ្នកជំងឺនេះបានស្លាប់។ ពេលគាត់ឃើញបូជាចារ្យបានលាបប្រេងដល់មនុស្សម្នាក់ ក្រោយមកគាត់មានគំនិតថាខ្ញុំចង់ធ្វើជាបូជាចារ្យដែរ។ តាមពិតប្លែក ប្រសិនបើយើងគិត ព្រោះយើងមិនចង់ធ្វើជាបូជាចារ្យដើម្បីឲ្យមនុស្សស្លាប់។ មានខ្លះគេថាចង់ធ្វើជាបូជាចារ្យ ដោយសារគេចង់ជួយអ្នកដទៃ ជួយអ្នកក្រីក្រ ចង់សម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់មនុស្សដែលខ្វះខាត គ្មានទីពឹងដែលមានជីវិតកម្សត់ទុរគត។ ប៉ុន្តែប្រយ័ត្ន យើងមិនធ្វើជាបូជាចារ្យ បងស្រី អ្នកបួស ដើម្បីចែករំលែកធម៌មេត្តាករុណារបស់ព្រះជាម្ចាស់មុនគេបង្អស់ គឺដើម្បីបង្ហាញថាជីវិតរបស់យើងមានតម្លៃដ៏ពិសេសបំផុតដោយសារយើងជាប់ជាមួយព្រះយេស៊ូ និងយើងចង់ឲ្យជីវិតហ្នឹងទៅដល់បងប្អូនឯទៀតៗ។ ពិសេសណាស់ កូនក្មេងនេះមិនចាប់អារម្មណ៍អ្នកគ្រោះថ្នាក់ដែលស្លាប់ ប៉ុន្តែចាប់អារម្មណ៍អំពីលោកឪពុក ដែលធ្វើអគ្គសញ្ញាសម្រាប់អ្នកជំងឺ ណែនាំឲ្យអ្នកស្លាប់នេះចូលនៅក្នុងស្ថានបរមសុខ ដើម្បីមានជីវិតអស់កល្បជានិច្ច។ គាត់បានឃើញជ្រៅណាស់ ជាហេតុដែលគាត់ចង់ធ្វើជាបូជាចារ្យ។ មិនធ្វើជាបូជាចារ្យដើម្បីជួយព្រោះអ្នកនោះស្លាប់ តែបូជាចារ្យនោះបានជួយពិសេស តាមរយៈអគ្គសញ្ញាបានណែនាំឲ្យបើកទ្វារនៃស្ថានបរមសុខ ដើម្បីឲ្យអ្នក

ស្លាប់នោះអាចភ្ជាប់ជាមួយព្រះជាម្ចាស់។ នេះជាមូលហេតុ យើងទាំងអស់ ជាបូជាចារ្យ ជាបងស្រី បានឆ្លើយតបទៅព្រះជាម្ចាស់យើងឯកភាព រស់នៅជាមួយព្រះយេស៊ូ នៅក្នុងរបៀបពិសេសមួយដោយយើងទទួលជីវិតពីព្រះអង្គយ៉ាងជិតស្និទ្ធបំផុត ដើម្បីចែករំលែកជីវិតហ្នឹងដល់បងប្អូនឯទៀតៗ។

«**ចូរស្ថិតនៅជាប់នឹងខ្ញុំ ដូចខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នាដែរ!**» ព្រះយេស៊ូបានជ្រើសរើសយើង ដើម្បីឲ្យយើងរស់នៅជាមួយព្រះយេស៊ូ និងដើម្បីឲ្យយើងជាប់ជាមួយព្រះយេស៊ូ។ នេះជាអ្វី ដែលណែនាំឲ្យជីវិតរបស់យើងពោរពេញដោយអំណរសប្បាយ មិនមែនអំណរសប្បាយមួយភ្លែតៗដែលលោកីយ៍ប្រគល់ឲ្យ ប៉ុន្តែជាអំណរសប្បាយដែលស្ថិតនៅជានិច្ច ជាអំណរសប្បាយមកពីព្រះយេស៊ូ។ ព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំមិនហើយបងប្អូនជាអ្នកបម្រើខ្ញុំ ជាទាសករ ចាប់ពីពេលនេះតទៅ បងប្អូនជាមិត្តសម្លាញ់របស់ខ្ញុំ និងខ្ញុំប្រទានឲ្យបងប្អូនទទួលអំណរសប្បាយ អំណរសប្បាយរបស់ខ្ញុំដែលស្ថិតនៅជានិច្ច**"។ នេះជាអំណរសប្បាយរបស់យើង ដោយសារព្រះយេស៊ូបានជ្រើសរើសយើងទាំងអស់គ្នា ជាគ្រីស្តបរិស័ទ លោកឪពុក ឬបងប្រុសបងស្រី ជាពិសេសយុវជន យើងយល់ថាព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ ដោយស្គាល់ឈ្មោះខ្ញុំ ដើម្បីឲ្យខ្ញុំទៅជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ឲ្យនៅជាប់ស្ថិតនៅជាមួយព្រះយេស៊ូជានិច្ច និងពោរពេញដោយអំណរសប្បាយដែលមកពីព្រះអង្គ។ មិនមែនអំណរសប្បាយល្មមៗដែលយើងដើរលេងជាមួយមិត្តភក្តិ អង្គុយលេង អង្គុយហូបបាយជាមួយគ្នា ឬទៅហាងទំនើបៗដែលមានយ៉ាងច្រើន ប៉ុន្តែអំណរសប្បាយដោយដឹងថា ជីវិតខ្ញុំភ្ជាប់ជាមួយព្រះយេស៊ូ ដង្ហើមខ្ញុំទទួលពីព្រះយេស៊ូ។ នៅក្នុងអត្ថបទទី១ "**ព្រះសហគមន៍កំពុងរីកចម្រើន នៅក្នុងសេចក្តីសុខសាន្ត នៅតាមកន្លែងនីមួយៗដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ជួយលើកទឹកចិត្តគេ**" នេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ យើងភ្ជាប់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធដែលណែនាំឲ្យយើងមានកម្លាំងថ្មី។

អត្ថបទទី២ "**យើងមិនត្រូវស្រឡាញ់ត្រឹមតែបបូរមាត់ឬពាក្យសម្ដីប៉ុណ្ណោះ គឺស្រឡាញ់តាមអំពើដែលយើងប្រព្រឹត្តនិងតាមសេចក្តីពិតវិញ**" នេះជាគោលការណ៍ គោលដៅដ៏ធំមែនទែន សម្រាប់ជីវិតរបស់យើងរៀងៗខ្លួន។ មិនមែនស្រឡាញ់ដោយបបូរមាត់ មិនមែនចេះតែថាៗអត់ដែលធ្វើ ប៉ុន្តែស្រឡាញ់ដោយពិតប្រាកដមែន ស្រឡាញ់ដោយសេចក្តីពិត និង

ដោយប្រព្រឹត្ត។ ណែនាំឲ្យជីវិតរបស់ព្រះយេស៊ូ អំណរសប្បាយរបស់ព្រះអង្គដែលប្រទានឲ្យយើង ទៅជាអំណរសប្បាយនិងជាជីវិតសម្រាប់មនុស្សយ៉ាងច្រើន។

នៅពេលនេះ ជាឱកាសដើម្បីបើកត្រចៀករបស់យើងស្តាប់ម្តងហើយម្តងទៀត ដើម្បីមើលម្តងហើយម្តងទៀត។ ស្តាប់ និងមើលព្រះយេស៊ូ ព្រះយេស៊ូ មិនមែននិមិត្តរូប (Idol) តាមលោកីយ៍ គឺសំខាន់បំផុតព្រះយេស៊ូណែនាំឲ្យយើងស្គាល់ព្រះបិតា ហើយណែនាំយើងឲ្យចូលក្នុងជីវិតយ៉ាងពិតប្រាកដរបស់យើង នៅក្នុងអត្ថន័យនៃជីវិតរបស់យើងតែម្តង។

សន្តិតេរេសានៃព្រះកុមារយេស៊ូ បានសរសេរបទចម្រៀងយ៉ាងពីរោះណាស់ "**ថ្ងៃនេះខ្ញុំរស់នៅសម្រាប់តែព្រះយេស៊ូ ថ្ងៃនេះខ្ញុំស្រលាញ់ព្រះយេស៊ូ ថ្ងៃនេះខ្ញុំបម្រើសម្រាប់ព្រះយេស៊ូ ថ្ងៃនេះខ្ញុំបម្រើបងប្អូនឯទៀតៗនៅក្នុងសេចក្តីស្រឡាញ់សម្រាប់ព្រះយេស៊ូ ថ្ងៃនេះខ្ញុំស្លាប់ជាមួយព្រះយេស៊ូ។ ថ្ងៃនេះខ្ញុំមើលឃើញនៅក្នុងស្ថានបរមសុខ**" ថ្ងៃនេះ ព្រះយេស៊ូត្រាស់ហៅយើង។ ថ្ងៃនេះ ព្រះយេស៊ូណែនាំឲ្យយើងស្ថិតនៅជាប់ជាមួយព្រះអង្គ ដើម្បីឲ្យជីវិតរបស់យើងមិនទៅជាជីវិតចង្អៀតចង្អល់ និងអាត្មានិយម តែណែនាំឲ្យជីវិតរបស់យើងក្លាយជាជីវិតទូលំទូលាយ ដោយសារព្រះជាម្ចាស់ចាប់ដៃយើង ទៅកាន់ពិភពដែលគ្មានព្រំដែន ដោយសេចក្តីស្រឡាញ់ទូលំទូលាយ។

នៅពេលនេះយើងស្តាប់ ស្តាប់ហើយយើងឆ្លើយ ឆ្លើយហើយយើងអនុវត្ត។ មិនមែនតាមបបូរមាត់ ប៉ុន្តែតាមសេចក្តីពិត និងប្រព្រឹត្តនៅក្នុងជីវិតរបស់យើង ដោយដឹងថាយើងត្រូវតែតស៊ូជានិច្ច។ ប្រសិនបើយើងមិនតស៊ូ មិនអត់ធ្មត់ មិនយកចិត្តទុកដាក់ យើងមិនអាចធ្វើអ្វីបានទេ។ ខ្ញុំអញ្ជើញបងប្អូនធ្វើដូចជាសន្តប៉ូល ឲ្យយើងទៅជាកីឡាកររបស់ព្រះជាម្ចាស់ កីឡាករតស៊ូណាស់ដើម្បីជោគជ័យ។ ព្រះយេស៊ូ អញ្ជើញយើងឲ្យទៅជាកីឡាកររបស់ព្រះអង្គ ដើម្បីរត់សម្រាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីណែនាំព្រះបន្ទូលរបស់ព្រះអង្គទៅគ្រប់ទីកន្លែង។ អស់មួយជីវិតរបស់យើងភ្ជាប់ជាមួយព្រះជាម្ចាស់ ដោយសារយើងទៅជាកីឡាករដ៏ពិសេសបំផុត ដូចព្រះយេស៊ូមានទឹកនិងឈាមចេញពីព្រះបេះដូងរបស់ព្រះអង្គនៅពេលព្រះអង្គសោយទិវង្គត។ ញើសនិងឈាមដែលណែនាំឲ្យបងប្អូនឯទៀតៗមានជីវិត។

ប្រសិនបើយើងអស់កម្លាំង ដោយសារយើងរត់មួយថ្ងៃដើម្បីព្រះជាម្ចាស់ ដោយសារយើងយកចិត្តទុកដាក់ស្រឡាញ់ លើកលែងទោស រស់នៅយកចិត្តចិត្តទុកដាក់ជាគ្រីស្តបរិស័ទក្នុងជីវិតប្រចាំ នៅពេលយើងចូលដេក យើងអស់កម្លាំងមែនតែដោយមានអំណរសប្បាយដ៏ពេញខ្លួន។ យើងអស់កម្លាំង ដោយសារយើងបានចេញអ្វីៗដែលយើងមាននៅក្នុងខ្លួនសម្រាប់ព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍ សម្រាប់បងប្អូនឯទៀតៗ។

សូមគិតពិចារណានៅពេលធ្វើដំណើរទៅវិញ ខ្ញុំបានឃើញព្រះយេស៊ូ ខ្ញុំបានស្តាប់ព្រះយេស៊ូ **តើខ្ញុំត្រូវធ្វើយ៉ាងម៉េច ដើម្បីធ្វើជាគ្រីស្តបរិស័ទល្អជាងមុន? តើខ្ញុំត្រូវធ្វើយ៉ាងម៉េច ដើម្បីក្លាយជាយុវជនល្អជាងមុន នៅក្នុងព្រះសហគមន៍ សង្គម កន្លែងដែលខ្ញុំរស់នៅ ដែលទទួលខុសត្រូវយ៉ាងខ្ពស់ណាស់ ដើម្បីបង្ហាញថាខ្ញុំមានមោទនភាពណាស់ ខ្ញុំមានកិត្តិយសណាស់ ដោយសារខ្ញុំមានមិត្តសម្លាញ់មួយដែលស្រឡាញ់ខ្ញុំបំផុតគឺព្រះយេស៊ូ?** សូមបងប្អូនដើរតាមព្រះយេស៊ូនឹងឃើញជីវិត សេចក្តីស្រឡាញ់ ឃើញព្រះបិតាផ្ទាល់។ អាម៉ែន៕